## **បត្យាប័ន** (Extradition) **១៖ ខ្លឹមសារទូទៅ**

១. បត្យាប័ន គឺជាដំណើរការដើម្បីបញ្ជូនបុគ្គលដែលគេទាមទារ[1] (wanted person) ពីប្រទេសមួយ (ប្រទេសទទួលសំណើ Requested State) ទៅប្រទេសធ្វើសំណើ (Requesting State) ដើម្បីធ្វើការវិនិច្ឆ័យសេចក្ដីដាក់ទោសទណ្ឌលើបុគ្គលដែលគេទាមទារ ឬឲ្យជននេះអនុវត្តទោស ដែលត្រូវបានប្រកាសជាស្ថាពរដោយតុលាការនៃប្រទេសធ្វើសំណើ។

២. ទីនេះ អ្នកសិក្សាគួរតែចែកឲ្យបានដាច់អំពីខ្លឹមសារនៃពាក្យពេចន៍ដែលពាក់ព័ន្ធ។ បត្យាប័ន ខុសអំពីពាក្យ deportation ដែលជាការបណ្ដេញចេញពីប្រទេសនូវជនបរទេស ដែលបានបំពានច្បាប់ ដូចជាការប្រព្រឹត្តបទល្មើស ឬការស្នាក់នៅហួសពេលកំណត់ដោយច្បាប់រំលោភច្បាប់ស្ដីពីអន្តោប្រវេសន៍។ សូមកុំច្រឡំនឹងពាក្យ expulsion ដែលសំដៅលើដីកាតាមច្បាប់ បញ្ជាឲ្យបណ្ដេញចេញ។ ពាក្យ «ការផ្ទេរឬបញ្ជូនដោយបង្ខំ (forced transfer)» សំដៅដល់ការបញ្ជូនមនុស្សម្នាក់ ឬមនុស្សមួយក្រុមដោយបង្ខំចេញពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតក្នុងរង្វង់ដែនដីប្រទេសតែមួយ។ ជាចុងក្រោយ យើងគួរកត់សំគាល់នូវពាក្យផ្ទេរទណ្ឌិត (transfer of prisoners) ដែលសំដៅពីការផ្ទេរទណ្ឌិតជាប់ពន្ធនាគារក្នុងប្រទេសមួយ មកអនុវត្តទោសក្នុងប្រទេសមួយទៀត (ប្រទេសដែលជននោះមានសញ្ជាតិ)។ ការបញ្ជូននេះ ត្រូវបានគ្រប់គ្រងដោយវិធានដោយឡែក។ ជាក់ស្ដែង ព្រះរាជាណាចក្រកម្ពុជា បានចុះកិច្ចព្រមព្រៀងជាមួយប្រទេសអូស្ត្រាលីក្នុងវិស័យនេះ (កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃប្រទេសអូស្ត្រាលីស្ដីពីការបញ្ជូនទណ្ឌិតឆ្នាំ២០០៦)[2]។

៣. បត្យាប័ន ត្រូវបានធ្វើឡើងតាមច្បាប់ឬសន្ធិសញ្ញាទ្វេភាគីឬពហុភាគី៖ *បត្យាប័នអាណិកជនបរទេស ដែលត្រូវចាប់ខ្លួននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិនៃសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិ ដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណី*

---

[1] Code of Criminal Procedure 2007, Article 585.

[2] Furthermore, the Kingdom of Cambodia has treaties with Viet Nam, Thailand and India in this respect, till 2025.

*គ្មានសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិ ដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជាទេ បទប្បញ្ញត្តិនៃជំពូកនេះ ត្រូវយកមកអនុវត្ត លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេងទៀត។*[3]

ក្នុងន័យនេះ ក្នុងករណីមិនមានអនុសញ្ញាឬសន្ធិសញ្ញាទេ បទប្បញ្ញត្តិស្តីពីបត្យាប័នក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនឹងត្រូវអនុវត្ត។ បន្ថែមពីលើនេះ ប្រសិនបើច្បាប់ផ្សេង មានចែងអំពីបត្យាប័ន ច្បាប់នោះនឹងអនុវត្ត។ ក្រមនីតិវិធីព្រហ្មទណ្ឌ អាចត្រូវចាត់ជាវិធានទូទៅ រីឯច្បាប់ស្តីពីការគ្រប់គ្រងសារធាតុញៀនឆ្នាំ ២០១២ (ជំពូកទី២៥, ផ្នែកទី១) ដែលក្នុងនោះមានចែងអំពីបត្យាប័ន គឺជាច្បាប់ពិសេស (*lex specialis*) ។ ព្រះរាជាណាចក្រកម្ពុជា បានចុះកិច្ចព្រមព្រៀងឬសន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសចំនួន៧ មកដល់ឆ្នាំ២០២៥ ពាក់ព័ន្ធបត្យាប័ន៖ សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ (១៩៩៩), សាធារណរដ្ឋប្រជាមានិតចិន (២០០០), សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (២០០៥), សាធារណរដ្ឋកូរ៉េ (២០១១), សាធារណរដ្ឋសង្គមនិយមវៀតណាម (២០១៤), សហព័ន្ធរុស្ស៊ី (២០១៨) និងសាធារណរដ្ឋបារាំង (២០២០)។ បន្ថែមពីលើនេះ ព្រះរាជាណាចក្រកម្ពុជាជាភាគីរបស់សន្ធិសញ្ញាពហុភាគី ដែលមានចែងអំពីកាតព្វកកិច្ចក្នុងការធ្វើបត្យាប័ន[4]។

៤. បទប្បញ្ញត្តិនៃច្បាប់និងសន្ធិសញ្ញាស្តីពីអំពីបត្យាប័ន ចែងអំពីបទល្មើសដែលអាចធ្វើបត្យាប័នបាន (extraditable offense) មូលដ្ឋានបដិសេធបត្យាប័ន, សំណើបត្យាប័ននិងលក្ខខណ្ឌអនុញ្ញាតឲ្យធ្វើបត្យាប័ន, នីតិវិធីនិងអាជ្ញាធរទទួលបន្ទុក, គោលការណ៍ dual criminality និង rule of specialty, ការឆ្លងកាត់ (transit) និងបញ្ហាមួយចំនួនទៀត។

**សូមអានបន្ថែមនូវអត្ថបទទី២ស្តីពីបទល្មើសដែលអាចធ្វើបត្យាប័នបាន**

[3] Code of Criminal Procedure 2007, Article 567.
[4] UN General Assembly, *Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment*, United Nations, Treaty Series, vol. 1465, p. 85, 10 December 1984, https://www.refworld.org/legal/agreements/unga/1984/en/13941 [accessed 12 April 2025]